**ព្រះរាជាណាចក្រកម្ពុជា**

**សាសនា ព្រះមហាក្សត្រ**

**3**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ ០០៤/០៨ កប/ស.ណ.ន

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តប្រកាសរួមលេខ ៣៣០ សកបយ ចុះថ្ងៃទី០៦/១២/២០០០ និងប្រកាសរួមលេខ ១៣៩ សកបយ ចុះថ្ងៃទី ២៨/០៦/២០០១

ក្នុងគោលបំណងលើកកំពស់បរិយាកាសជឿទុកចិត្តគ្នាជួយគ្នា និងយោគយល់គ្នា ដើម្បីឈានទៅបង្កើន អាជីវកម្ម ផលិតកម្មរក្សាបានល្អនូវទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងអាចដោះស្រាយការលំបាករបស់កម្មករ

និយោជិត ពេលមាន បញ្ហាសុខភាព និយោជក និងកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថាន ទាំងអស់ ដែលស្ថិតក្នុង ដែនអនុវត្តនៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់អនុវត្តដូចតទៅៈ

១-និយោកជកគ្រប់សហគ្រាស គ្រឹះស្ថាន ត្រូវរៀបចំឱ្យមានគិលានដ្ឋាន ដូចមានចែង ក្នុងប្រកាសរួម ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា និងក្រសួងសុខាភិបាល លេខ ៣៣០ សកបយ ចុះថ្ងៃទី០៦/១២/២០០០ ស្តីពី ការរៀបចំគិលានដ្ឋានសហគ្រាស ។

២-និយោជកគ្រប់សហគ្រាស គ្រឹះស្ថាន ត្រូវពិនិត្យ ពិចារណាស៊ីជំរៅ ទៅលើ ប្រកាសរួម ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា និងក្រសួងសុខាភិបាល លេខ ១៣៩ សកបយ ចុះថ្ងៃទី ២៨/០៦/២០០១ ស្តីពីល័ក្ខខ័ណ្ឌនិងបេសកម្មសេវាពេទ្យសហគ្រាស ដោយយកចិត្តទុកដាក់ដល់ការផ្តល់ ឱកាសនិងផ្តល់សិទ្ធិគ្រប់គ្រាន់ ឱ្យគ្រូពេទ្យសហគ្រាស អាចបំពេញភារកិច្ចបានត្រឹមត្រូវ ។

៣-និយោជក នៃសហគ្រាស គ្រឹះស្ថាន មានកាតព្វកិច្ច ជួយគិតគូរ បង្កលក្ខណៈងាយស្រួល ដល់កម្មករ និយោជិត របស់ខ្លួន នៅពេលដែលកម្មករនិយោជិតនោះ មានគ្រោះថ្នាក់ការងារ ឬមានជំងឺ ដោយធ្វើយ៉ាង ឱ្យគេអាចមានលទ្ធភាពនិងមានឱកាសអាចទទួលបានការពិនិត្យព្យាបាលដោយសមរម្យ ។

៤-កម្មករនិយោជិត ត្រូវតែមានភាពស្មោះត្រង់ នៅពេលដែលខ្លួនអាក់ខានមិនបានមកធ្វើការតាមកិច្ច សន្យាការងារ ដោយមូលហេតុសុខភាព និងនៅឆ្ងាយពីកន្លែងធ្វើការ ត្រូវរកគ្រប់មធ្យោបាយជូនដំណឹងទៅ សហគ្រាស គ្រឹះស្ថាន ឱ្យបានដឹងទាន់ពេលវេលា ។ ការអាក់ខាន មិនបានបំពេញកាតព្វកិច្ចនេះ ត្រូវមាន មូលហេតុសមស្រប ។

៥-និយោជក ព្រមទាំងកម្មករនិយោជិត ត្រូវសហការគ្នាពិគ្រោះ ពិចារណាទៅលើបទបញ្ជាផ្ទៃក្នុងសហគ្រាស និងបែបបទចាំបាច់ នៅពេលមានជំងឺ ឬមានគ្រោះថ្នាក់ ។

ទទួលបានសារាចរណែនាំនេះ គ្រប់សហគ្រាស គ្រឹះស្ថាន ព្រមទាំងកម្មករនិយោជិត ត្រូវសហការគ្នាអនុវត្តតាមខ្លឹមសារទាំងឡាយនៃសារាចរនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

ចម្លងជូនៈ

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យឯឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន

-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន

-អាជ្ញាធរជាតិប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍

-គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋានការងារ

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ

-គ្រប់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង

" ដើម្បីផ្សព្វផ្សាយនិងអនុវត្ត "

-សមាគមនិយោជក និងសហគមពាណិជ្ជកម្មកម្ពុជា " ដើម្បីអនុវត្ត "

-គ្រប់សហព័ន្ធសហជីព " ដើម្បីជូនជ្រាប "

-គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "

-កាលប្បវត្តិ និងឯកសារ